**រាជបណ្ឌិត្យសភាកម្ពុជា**

# វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## - ភាគទី ៣ -



អត្ថបទចងក្រងដោយៈ លោកស្រី **ស៊ិន ច័ន្ទអមរា**
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

-២០១៩-

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## (ភាគទី ៣)

អត្ថបទចងក្រងដោយៈ លោកស្រី **ស៊ិន ច័ន្ទអមរា**
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

នៅក្នុងភាគទី២នៃអត្ថបទ យើងបានបង្ហាញអំពី«បណ្ណសារ»(Archive)មួយ ដែលជាលិខិតរបស់ឧកញ៉ាវាំងជូនទៅលោករេស៊ីដង់ជាន់ខ្ពស់បារាំង ចុះថ្ងៃទី១៣ ខែមីនាឆ្នាំ១៩១៦(សូមមើលអត្ថបទមុន)។

ចំណែកនៅភាគទី៣នេះ សូមបង្ហាញ«បណ្ណសារ»(ឯកសារប្រភពទី១)មួយទៀត គឺព្រះរាជ ឱង្ការរបស់ព្រះបាទស៊ីសុវត្ថិ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩១៧[1]។ ដើម្បីឱ្យកូនខ្មែរបច្ចុប្បន្នបានស្គាល់នូវ ពាក្យពេចន៍ ដែលជាពាក្យកម្រងកែវជាច្រើនអន្លើគួរឱ្យជក់ចិត្ត និងអក្ខរាវិរុទ្ធខ្មែរ កាលពី១០២ឆ្នាំមុននោះ យើងសូមបង្ហាញអត្ថបទស្ដីពីព្រះរាជឱង្ការដែលមានខ្លឹមសារដើម ដោយសម្រួលនិងពន្យល់តែពាក្យ ពិបាកមួយចំនួនដូចតទៅៈ

### ព្រះរាជឱង្ការ ព្រះចៅសម្ដេច ព្រះស៊ីសុវត្ថិៈ

*ត្រាស់លើត្បូង[2] ព្រះបរមរាជវង្សានុវង្ស អគ្គអគ្គមហាសេនាបតី នាម៉ឺនសព្វមុខមន្ត្រីក្នុងក្រុង ក្រៅក្រុង ចៅហ្វាយស្រុក ក្រមការខេត្ត ក្រមការឃុំ នៅអស់អាណាប្រជានុរាស្ត្រគ្រប់សាសន៍គ្រប់ភាសាក្នុងក្រុងកម្ពុជាឱ្យបានដឹង។*

*ត្បិតព្រះនគរក្រុងបារាំងសែស ដែលមានហទយវត្ថុ[3]សប្បុរសរីកទូលាយជួយទំនុកបម្រុងការពារព្យាបាលយើងនោះ បានធ្វើការសង្គ្រាម តតាំងច្បាំងនឹងនគរអាល្លឺម៉ង់ តាំងអំពី៣ឆ្នាំរៀងមកដល់ឥឡូវ ក៏នៅទ្រទ្រង់យុទ្ធនាការតទៅទៀត។*

*ដើម្បីនឹងជួយទំនុកបម្រុងការពារអស់ទាំងប្រទេស និងនគរផងនា។ ឱ្យរួចពីដៃបច្ចាមិត្ត ដែលគិតបៀតបៀនសង្កត់សង្កិន ដោយសេចក្ដីលោភលន់ពន់ប្រមាណ។*

---

[1]ព្រះរាជឱង្ការ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩១៧ នៅក្នុងរាជកិច្ចរាជការ, សេចក្ដីក្នុងរាជការ, ចំណែកទី១, លេខ៤ ខែតុលា-វិច្ឆិកា-ធ្នូ ឆ្នាំ១៩១៧, ទំព័រ២៤១-២៤៧។

[2]ត្រាស់លើត្បូង គឺត្រាស់បង្គាប់ចំពោះ...។

[3]ហទយវត្ថុ គឺលំនៅរបស់ចិត្ត(តួបេះដូង) តាមវចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧, ទំព័រ១៥០៩។

*សព្វថ្ងៃនេះបានទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ថាកងសេនាទាហានបារាំងសែស ហើយនិង កងសេនាទាហានសម្ព័ន្ធមិត្តគ្រប់នគរឯករាជ្យ ដែលលើកមកប្រសព្វសន្តវៈ[4] ប្រឹងប្រួតពួតដៃចូលជួយនោះបានឃាត់ឃាំងរាំងរាកងទ័ពអាល្លឺម៉ង់មិនឱ្យរុករានទន្ទ្រានចូលមក ប្ញន់យកទីដីរបស់ព្រះមហានគរជាមាតា[5]យើងនោះឃាត់ទុកឱ្យនៅនឹងបានហើយៗ ថែមទាំងរុករានទន្ទ្រានច្រានថយទៅវិញ ជាច្រើនកើនឡើងមិនដាច់ ដោយមានជ័យជម្នះយ៉ាងរុងរឿងថ្កើងល្បីកិត្តិសព្ទជាច្រើនក្តា[6]ៗ*

*ក្នុងខណៈនេះទ្រង់ព្រះតម្រិះយល់ថា ត្រូវតែខំប្រឹងប្រួត ឱ្យអស់ពីកម្លាំងពលំពល់ខ្លួន ដើម្បីនឹងបង្ក្រាបនគរអាល្លឺម៉ង់ ឱ្យបាក់បបខ្ទេចខ្ទីរាបទាប កុំឱ្យកម្រើកងើបឡើងវិញបានៗ បើដូច្នេះទើបនឹងមានសេចក្តីសុខក្សេមក្សាន្ត ក្នុងពិភពលោកកីយនេះ ជាទៀងរៀងតទៅៗ*

*ឯអស់ទាំងនគរក្នុងទ្វីបអាស៊ី ជាដើមប្រធានមាននគរយួននិងនគរខ្មែរយើងបានកេណ្ឌកងសេនាទាហាន និងពួកជាងជាជំនួយដោយស្ម័គ្រចិត្តបញ្ជូនទៅជួយមហានគរក្រុងបារាំងសែស ក្នុងគ្រាដែលខំប្រឹងធ្វើការសង្គ្រាមនេះហើយៗពួកកងសេនាទាហានទាំងនោះ ក៏បានសម្តែងឱ្យឃើញអំពីចិត្តហានក្លា ហើយនិងសេចក្តីកតញ្ញូស្ម័ជាមួយនឹងព្រះមហានគរជាមាតា ដំណើរនោះជាពិតមែនហើយៗ*

*ឯនគរក្រុងចិន ហើយនិងក្រុងសៀមក៏បានប្រកាសសង្គ្រាមច្បាំងនឹងនគរអាល្លឺម៉ង់ហើយៗ សព្វថ្ងៃនេះកំពុងតែប្រុងប្រៀបរៀបចូលទៅជួយច្បាំងនោះៗ*

*ឯនគរអាមេរិកសព្វថ្ងៃក៏ប្រុងប្រៀប កងសេនាទាហានមានមនុស្សរាប់លានមានបម្រុងទុកបញ្ជូនមកជួយសម្ព័ន្ធមិត្តឱ្យបានមានជ័យជម្នះជាស្រេចៗ*

*ក្នុងគ្រានេះការសង្គ្រាមឃើញថា បានចម្រើនដូចប្រាថ្នាជាប្រាកដៗ*

*ឯនគរអាល្លឺម៉ង់សព្វថ្ងៃនេះ និងអាចរុករានទន្ទ្រានមកទៀតនោះពុំបានឡើយគឺខំគ្រាន់តែទប់ទល់ឱ្យនៅបានយូរដើម្បីគេចឱ្យរួចពីទោស ដែលខ្លួនប្រព្រឹត្ត...ៗ*

---

[4] ប្រសព្វសន្តវៈ គឺរួមចិត្តគំនិត រួមសុខទុក្ខៗ

[5]ព្រះមហានគរជាមាតា គឺប្រទេសបារាំងៗ

[6]ច្រើនក្តា គឺច្រើនដងៗ

បើនឹងគិតធ្វើឱ្យការសង្គ្រាមនេះឆាប់ហើយស្រេចបាននោះ មានតែត្រូវរកធនធានឱ្យបានជាច្រើន កើនឡើងថែមទៀត ផ្គត់ផ្គង់ព្រះមហានគរបារាំងសែស។ឯរកធនធានផ្គត់ផ្គង់ដូច្នេះ មានតែរកខ្ចីចងការ ម្តងទៀត។

ហេតុដូច្នេះទើបទ្រង់ព្រះរាជតម្រិះយល់ថានគរក្រុងកម្ពុជាយើងនេះ បានព្រះមហានគរក្រុងបារាំងសែស មកទំនុកបម្រុងព្យាបាលឱ្យសុខសប្បាយក្សេមក្សាន្តតាំងអំពី៩០ឆ្នាំនេះមកហើយ ដូច្នេះត្រូវតែជួយព្រះមហានគរជាមាតាឱ្យជានិច្ច គឺជួយដោយឱ្យខ្ចីប្រាក់ទាំងប៉ុន្មានដែលព្រះបរមរាជវង្សានុវង្ស អគ្គអគ្គមហាសេនាបតីនាម៉ឺនសព្វមុខមន្ត្រីនិងអស់អាណាប្រជានុរាស្ត្រក្នុងព្រះនគរ ដែលមានប្រាក់នឹងខ្ចីចងការបាននោះ ត្រូវចងការជូនព្រះមហានគរជាមាតាទាំងអស់។

សព្វថ្ងៃនេះយើងបានអ្វីជាបន្ទាល់ឱ្យប្រាកដ ថាយើងមានចិត្តសុចរិតកតញ្ញូដឹងគុណហើយស្លូតទៀងត្រង់នឹងព្រះមហានគរ ដែលទំនុកបម្រុងព្យាបាលយើងនោះ មានតែចងការប្រាក់ជូនទើបឃើញថាមានបន្ទាល់ពីចិត្តដូច្នោះជាប្រាកដ។

គឺចងការប្រាក់ជូនព្រះមហានគរដើម្បីការពារឱ្យបានសុខសប្បាយអំណឹះតទៅ ដល់កូនចៅយើងឯមុខ ឱ្យបានមានកព្វព្រេងសំណាងរាល់គ្នា។

សេចក្តីនេះទ្រង់ព្រះតម្រិះយល់ថា អស់ទាំងព្រះបរមរាជវង្សានុវង្ស អគ្គអគ្គមហាសេនា។បតី នាម៉ឺនសព្វមុខមន្ត្រីក្រមការខេត្ត ក្រមការឃុំ និងបណ្តាអស់អាណាប្រជានុរាស្ត្រក្នុងមហានគរគ្មាននរណាមួយអាចនឹងប្រកាន់ប្រកែក រឹងទទឹងមិនព្រមចងការប្រាក់ជូន ព្រះមហានគរបារាំងសែស ដែលត្រូវការចាយប្រាក់ ហើយក្រុងបារាំងសែសនឹងសងទាំងដើមទាំងការវិញ នៅវេលាគ្រាដែលហើយការសង្គ្រាមនោះទ្រង់ព្រះរាជតម្រិះយល់ថា គឺគ្មាននរណាមួយនឹងប្រកែកអំពីប្រការដូច្នេះឡើយ។

បើដូច្នេះ ចូរអស់ព្រះបរមរាជវង្សានុវង្ស អគ្គអគ្គមហាសេនា។បតី នាម៉ឺនសព្វមុខមន្ត្រីក្នុងក្រុង ក្រៅក្រុង និងចៅហ្វាយស្រុក ក្រមការខេត្ត ក្រមការឃុំ នៅអស់អាណាប្រជានុរាស្ត្រទាំងប៉ុន្មាន ដែលពឹងក្រោមម្លប់ព្រះបរមពោធិសម្ភារ[7] ចូរស្តាប់

[7] ពោធិសម្ភារ គឺតេជៈបារមី, អំណាបុណ្យ ឬទីពឹងពំនាក់ (សម្រាប់ថ្លែងសេចក្តីសសើរតេជៈព្រះមហាក្សត្រយ៍, ឧទាហរណ៍ ពឹងក្រោមម្លប់ព្រះបរមពោធិសម្ភារ) តាមវចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧, ទំព័រ៧៧៩។

*ត្រាប់តាមព្រះរាជឱង្ការនេះ ដោយសប្បុរសរីកទូលាយតម្កល់ទុកក្នុងចិត្ត ប្រៀបដូចសេចក្ដីបង្គាប់ ដែលជាទីរាប់អានគួរធ្វើសក្ការបូជា។*

*ចូរបណ្ដារាល់គ្នាដែលជាអ្នកមានក្ដី អ្នកខ្សត់ក្ដី ជានាម៉ឺនសព្វមុខមន្ត្រីក្នុងរាជការក្ដី ចូរឱ្យខ្មីចងការប្រាក់ជូនព្រះមហានគរក្រុងបារាំងសែស តាមកម្លាំងធនធានដែលខ្លួនមានរាល់គ្នា។*

*ត្បិតខ្លួននៅទីនេះជាមហាសុខឥតមានរងទុក្ខភិតភ័យ និងការសង្គ្រាមជាធំដំរន្ធត់ស្ងប់ស្ងែងនេះឡើយ ហើយទ្រព្យសម្បត្តិនិងរូបកាយខ្លួនរាល់គ្នា បានព្រះនគរជាមាតាដ៏មានបារមីថ្កើងរុងរឿងជួយទំនុកបម្រុងការពារស៊ូជីវិតឥតក្ញេច។ល។*

*ឯព្រះរាជឱង្ការនូវព្រះបន្ទូលនេះ ចូរឱ្យប្រណិបត្តិតាមគ្រប់គ្នា កុំបីធ្វេសប្រហែសឡើយ។*

*ធ្វើក្នុងព្រះបរមរាជវាំងចតុមុខក្រុងភ្នំពេញ ត្រាសប្រាប់មកនៅថ្ងៃ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ នពស័ក ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩១៧។*

*បានឃើញហើយយល់ព្រមផង* **ស៊ីសុវត្ថិ**

*ឡឺរេស៊ីដង្ត សុប៉េរីយើរ*

**បូដូវាំង**

(សូមរង់ចាំអានភាគបន្ត...)